ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន

## ទិវាពិភពលោក ដើម្បីសុខភាព និងសុវត្ថិភាពការងារ ២៨មេសា ក្រោមប្រធានបទ "បង្កើនសុក្រឹត្យភាពក្នុងការប្រមូល និងប្រើប្រាស់ទិន្នន័យសុខភាព និងសុវត្ថិភាពការងារ"

## ខេត្តសៀមរាប ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយសហការជាមួយសាលាខេត្តសៀមរាប និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) នឹងរៀបចំទិវាពិភពលោក ដើម្បីសុខភាព និងសុវត្ថិភាពការងារ ២៨មេសា ក្រោមប្រធានបទ "**បង្កើនសុក្រឹត្យភាពក្នុងការប្រមូល និងប្រើប្រាស់ទិន្នន័យសុខភាព និងសុវត្ថិភាពការងារ**" និងពិធីសំណេះសំណាលជាមួយកម្មករនិយោជិតក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១៣១ នៃទិវាពលកម្មអន្តរជាតិ ១ឧសភា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ នៅអង្គរយុងយូ ខេត្តសៀមរាប។

នេះជាឆ្នាំទី១២ហើយ ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រារព្ធទិវាពិភពលោក ដើម្បីសុខភាព និងសុវត្ថិភាពការងារ ក្នុងគោលបំណងផ្សព្វផ្សាយ អំពីទំហំនៃគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ និងបំផុសការយល់ដឹងជាសាធារណៈ ស្តីពីសុខភាព និងសុវត្ថិភាពការងារ ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៅកន្លែងធ្វើការ ព្រមទាំងទាញការគាំទ្រពីស្ថាប័នពាក់ព័ន្ធ អង្គការនិយោជក និងអង្គការកម្មករនិយោជិត។

ទិវានេះ នឹងមានការចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **ឯកឧត្តមបណ្ឌិត ឃឹម ប៊ុនសុង** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងតំណាងអង្គការអន្តរជាតិខាងការងារ ព្រមទាំងតំណាងស្ថាប័នពាក់ព័ន្ធ ម្ចាស់សហគ្រាស គ្រឹះស្ថាននានា និងកម្មករនិយោជិត នៅក្នុងខេត្តសៀបរាប សរុបចំនួនជាង ១៣០០នាក់។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៧

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩